**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការដាក់ឱ្យដំណើរការប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ តាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមជម្រាបជូន ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមូលដ្ឋានសុខាភិបាលសាធារណៈ ជ្រាបថា៖ ក្រសួងនឹងដាក់ឱ្យដំណើរការប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ តាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដែលចាប់ផ្តើមអនុវត្តជាផ្លូវការនៅ**ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២** តទៅ។

ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ត្រូវបានបង្កើតឡើងក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ជាពិសេសជួយសម្រួលមន្ត្រីគ្រប់គ្រងកម្មវិធី និងអនុវត្តកម្មវិធីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងស្ថានប័នពាក់ព័ន្ធនានា ក្នុងការប្រមូលទិន្នន័យ បញ្ចូលទិន្នន័យ ពិនិត្យមើលទិន្នន័យ និងបញ្ចេញរបាយការណ៍ទិន្នន័យបានលឿនរហ័ស ជូនថ្នាក់ដឹកនាំដើម្បីជាមូលដ្ឋានសម្រាប់ធ្វើការពិចារណា ធ្វើសេចក្តីសម្រេចចិត្ត កែសម្រួលយុទ្ធសាស្ត្រ និងឆ្លើយតបបញ្ហានានាទាន់ពេលវេលា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត** មេត្តាជូនដំណឹង និងផ្តល់ការគាំទ្រដល់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមក្រុង ស្រុក ខណ្ឌ រដ្ឋបាល ឃុំ សង្កាត់ និងមូលដ្ឋានសុខាភិបាលសាធារណៈ ចាប់ផ្តើមអនុវត្តប្រើប្រាស់ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ចន្ទ ១៥រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០២២